**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សារថ្វាយព្រះពរ**
**សូមក្រាបបង្គំទូលថ្វាយ**
**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**
**ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**

**សម្តេចព្រះមហាក្សត្រី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** !

ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី** គម្រប់ **៧៩** យាងចូល **៨០**ព្រះវស្សា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៥ ខាងមុខនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានបីតិសោមនស្សរីករាយ សូមថ្វាយព្រះសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនាដ៏មហាប្រសើរថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី** សូមព្រះអង្គប្រកបដោយ ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះប្រាជ្ញាស្មារតីឈ្លាសវៃ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ត្រជុំដល់ប្រជារាស្ត្រខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវភក្តីភាពប្រកបដោយកតញ្ញូតាធម៌ តបស្នងព្រះមហាករុណាទិគុណដ៏ធំធេងក្នុងមនោសញ្ចេតនាគោរពដឹងគុណដ៏ជ្រាលជ្រៅចំពោះសម្តេចម៉ែ ដែលព្រះអង្គបានលះបង់ព្រះកាយពល ព្រះបញ្ញាញាណក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម ដើម្បីបុព្វហេតុជាតិមាតុភូមិអង្គរជាទីស្នេហា ពិសេសលើវិស័យមនុស្សធម៌ អប់រំ សង្គមកិច្ច និងសុខុមាលភាពទូទៅរបស់ប្រជារាស្ត្រជាកូនចៅ ចៅទួតរបស់ព្រះអង្គជារៀងដរាប។

ទូលព្រះបង្គំសូមលើកហត្ថប្រណម្យបួងសួងដល់ទេវតាឆ្នាំថ្មី ឆ្នាំមមែ គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក និងដួងព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ តាមជួយអភិបាលប្រោសព្រំព្រះសព្ទសាធុការពរជ័យគ្រប់ប្រការថ្វាយ **សម្តេចព្រះមហាក្សត្រី** សូមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥

**ប្រាក់ សុខុន**
**រដ្ឋមន្ត្រី និងជាតំណាងមន្ត្រីរាជការគ្រប់ថ្នាក់នៃ**
**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**